# ការរីករាយជាមួយនឹងព្រះជាម្ចាស់



ការរកឃើញមួយដ៏អស្ចារ្យបំផុតដែលខ្ញុំបានធ្វើបន្ទាប់មកទៀត ដែលជាផ្នែកមួយនៃជីវិតគ្រិស្តបរិស័ទរបស់ខ្ញុំ គឺសារៈសំខាន់នៃការរីករាយជាមួយនឹងព្រះជាម្ចាស់។ នៅសតវត្សរ៍ទី១៧ មេដឹកនាំគ្រិស្តបរិស័ទមួយក្រុម មកពីព្រះវិហារមួយចំនួនក្នុងចក្រភពអង់គ្លេស និងស្កុតឡេន បានជួបជុំគ្នា ដើម្បីកំណត់នូវអ្វីដែលសំខាន់បំផុតក្នុងជីវិត និងការអនុវត្តរបស់គ្រិស្តបរិស័ទ។ ការលើកឡើងមួយបានគូសបញ្ជាក់ថា គឺជាសារៈសំខាន់នៃការ «ថ្វាយសិរីល្អដល់ព្រះជាម្ចាស់

និងការរីករាយជាមួយព្រះអង្គអស់កល្បជានិច្ច!»។ ការថ្វាយសិរីរុងរឿង

មានន័យថា ការលើកតម្កើង ការថ្វាយកិត្តិយស និង ការសរសើរតម្កើង ។

ពួកមេដឹកនាំសាសនាជាច្រើនាក់នៅជំនាន់ព្រះយេស៊ូបានបដិសេធនូវព្រះបន្ទូលរបស់ទ្រង់។ តើមនុស្សជាច្រើនទៀត បានឆ្លើយតបយ៉ាងដូចម្ដេចទៅកាន់ព្រះអង្គ?



សូមអាន *ម៉ាកុស ១២:៣៧* ______________________________

## គំរូនៅក្នុងព្រះគម្ពីរ

សូមអានទំនុកដំកើង បទចម្រៀងសាឡូម៉ូន (វាមានអត្ថន័យស្របគ្នាស្ដីពីទំនាក់ទំនងសេចក្ដីស្រឡាញ់រវាងព្រះជាម្ចាស់និងអ្នកជឿព្រះអង្គ) រួមជា មួយនឹង ឧទាហរណ៍ និងដំណើររឿងជាច្រើនទៀតនៅក្នុងព្រះគម្ពីរ។ សារៈសំខាន់ក្នុងការមានទំនាក់ទំនងដ៏រីករាយជាមួយនឹងព្រះជាម្ចាស់ នៅតែមានជានិច្ច ទោះជានៅពេលអ្នកនិពន្ធជួបប្រទះនូវការល្បងលក៏ដោយ។ ទាំងនេះជាឧទាហរណ៍ មួយចំនួនអំពីអំណរនៅពេលដែលមនុស្សមានកិច្ចជួបជាមួយនឹងព្រះជាម្ចាស់៖

*ប្រាកដជាសេចក្ដីសប្បុរស និងសេចក្ដីមេត្តាករុណា នឹងជាប់តាមខ្ញុំរាល់តែថ្ងៃដរាបដល់អស់១ ជីវិតខ្ញុំ ហើយខ្ញុំនឹងនៅក្នុងដំណាក់នៃព្រះយេហូវ៉ាជារៀងដរាបទៅ ។ ទំនុកដំកើង ២៣:៦*

*... ព្រោះអំណរដែលមកពីព្រះអម្ចាស់ ជាកម្លាំងរបស់អ្នករាល់គ្នា»។ នេហេមា ៨:១០*

*“តើយើងខ្ញុំអាចនឹងអរព្រះគុណដល់ព្រះ ពីដំណើរអ្នករាល់គ្នា ដោយប្រការដូចម្ដេច ឲ្យបានល្មមជូននឹងអស់ទាំងសេចក្ដីអំណរ ដែលយើងខ្ញុំមាននៅចំពោះព្រះនៃយើង ដោយព្រោះអ្នករាល់គ្នាបាន” ១ ថែស្សាឡូនីច ៣:៩*

*“ចូរអរសប្បាយជានិច្ច ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យឲ្យអ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រិស្តយេស៊ូ” ១ ថែស្សាឡូនីច៥:១៦,១៨*

## ព្រះជាម្ចាស់សំដែងអង្គទ្រង់ឲ្យយើងបានស្គាល់

លោក ឌីហ្សឹមDeism ជាអ្នកទស្សនវិជ្ជាម្នាក់បានលេចធ្លោក្នុងអំឡុងសតវត្សទី១៧ និងសតវត្សទី១៨ លោកសន្និដ្ឋានថា ព្រះជាម្ចាស់គ្មានសណ្ឋានរូបរាង ហើយមនុស្សមិនអាចស្គាល់ទ្រង់បានទេ ។ មិនខុសពីគំនិត

ស្តីពីអ្នកផលិតនាឡិកា ដែលបានផលិតនាឡិការួច បញ្ជូននាឡិកានោះទៅកាន់អតិថិជនដែលនៅឆ្ងាយៗ ហើយគាត់មិនដែលបានឃើញនាឡិកានោះម្តងទៀត ។

ប៉ុន្តែ ព្រះជាម្ចាស់របស់យើងជាព្រះ ដែលបានយកកំណើតជាមនុស្ស (យកភាពជាមនុស្ស) នៅក្នុងព្រះយេស៊ូ ហើយឥឡូវនេះយើងដឹងថាទ្រង់ជានរណា ។ ព្រះអង្គបានបើកសំដែងអោយមនុស្សអាចស្គាល់ទ្រង់ ហើយមុន ពេលទ្រង់យាងចេញពីផែនដី ព្រះអង្គបានបង្រៀនពីគោលការណ៍សំខាន់ៗជាច្រើន ដែលបានកត់ត្រានៅក្នុង គម្ពីរយ៉ូហាន ជំពូក១៣-១៦ អំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយនឹងព្រះវរបិតា និង រាស្ត្ររបស់ទ្រង់ ។

តើព្រះយេស៊ូបានអះអាងយ៉ាងដូចម្តេចខ្លះ នៅក្នុងគម្ពីរ *យ៉ូហាន ១២:៤៤-៤៥* និង *យ៉ូហាន ១៤:១១* ________________________________

សព្វថ្ងៃនេះ ព្រះយេស៊ូមានព្រះជន្មរស់នៅក្នុងចំណោម និងក្នុងរាស្ត្ររបស់ទ្រង់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវត្តមានគង់នៅនៃព្រះវិញ្ញាណបរិសុទ្ធ បានផ្តល់ឱ្យយើងនូវទំនាក់ទំនងដ៏ស្និទ្ធស្នាលបំផុត ។

តើមានន័យយ៉ាងដូចម្តេច? សូមអាន *យ៉ូហាន ១៤:២៣, ១៦:៧*

________________________________________

យើងមិនចាំបាច់ត្រូវខំប្រឹងឲ្យបានក្តីស្រឡាញ់របស់ព្រះអង្គមកនោះទេ ដ្បិតយើងទទួលបានសេចក្តីស្រឡាញ់របស់ព្រះអង្គរួចទៅហើយ !

## ធ្វើជាមិត្តសម្លាញ់ជាមួយនឹងព្រះជាម្ចាស់ តើជាការដែលអាចទៅរួចដែរឬទេ?

តើនរណាក្លាយជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ នៅក្នុងបទគម្ពីរយោងទាំងនេះ?

១. អេសាយ ៤១: ៨ ____________________

២. យ៉ូហាន ១៥:១៥ ____________________

ជួនកាលមិត្តភាពនេះ គឺបានលើកមកបង្ហាញនៅក្នុងព្រះគម្ពីរនៅពេលដែលជាមនុស្ស



«ដើរជាមួយនឹងព្រះជាម្ចាស់» រួមមានលោកអេណុក *(លោកុប្បត្តិ ៥:២២)* និង លោកណូអេ *(លោកុប្បត្តិ ៦:៩)* ។

នេះមិនមែនមានន័យថាពួកគេជាមនុស្សដែលល្អឥតខ្ចោះនោះទេ ដ្បិតពួកគេមិនល្អឥតខ្ចោះនោះឡើយ ។

ការបង្កើតចំណងមិត្តភាពជាមួយនឹងព្រះជាម្ចាស់ គឺជាការធ្វើតាមគោលការណ៍ដ៏សំខាន់មួយចំនួនដូចបានរៀបរាប់នៅក្នុងកូនសៀវភៅ ភាពជាសាវ័ក។ វាមិនមានន័យថាជាការធ្វើដោយបង្ខំចិត្តនោះទេ ប៉ុន្តែដោយការរីករាយពេញចិត្ត ដែលទទួលបាននូវក្តីស្រឡាញ់ ការជ្រើសរើស ការអត់ទោស ព្រមទាំងមានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គង់នៅក្នុងយើងជានិច្ច។ យើងជាកូនប្រុស កូនស្រី របស់ព្រះជាម្ចាស់ ដែលបានទទួលចិញ្ចឹមចូលមកក្នុងគ្រួសាររបស់ព្រះអង្គ។ *(យ៉ូហាន ១:១២ អេភេសូរ ១:៥)*

អារម្មណ៍នៃទំនាក់ទំនងដ៏ជិតស្និទ្ធរបស់យើងកើតមាន ដោយការរស់នៅក្នុងបរិយាកាសនៃការអធិស្ឋានឥតឈប់ឈរ ការសញ្ជឹងគិតពីបទគម្ពីរ ការស្តាប់បង្គាប់តាមព្រះគ្រិស្ត និងសេចក្តីបង្រៀនរបស់ព្រះអង្គ ជាប់នៅក្នុងការបម្រើព័ន្ធកិច្ចគ្រិស្តបរិស័ទ និងការធ្វើជាស្មរបន្ទាល់ដល់អ្នកដទៃ។ មានពេលខ្លះ ព្រះវត្តមានរបស់ព្រះគ្រិស្តហាក់ដូចជាច្បាស់ៗ ហើយពេលផ្សេងទៀត យើងត្រូវទទួលព្រះវត្តមានព្រះអង្គដោយជំនឿ ទាំងដឹងថាទ្រង់នឹងមិនដែលចាកចេញពីយើង ក៏នឹងមិនដែលបោះបង់ចោលយើងឡើយ ។ *(ហេព្រើរ ១៣:៥)*

នៅក្នុងយ៉ូហានជំពូក ១៥ រៀបរាប់អំពីសារៈសំខាន់របស់ខ្នែងដើម្បីឲ្យវាអាចបង្កើតផលផ្លែបានគឺត្រូវតែនៅជាប់នឹងដើមទំពាំងបាយជូរ។ សម្រាប់អ្នកជឿ គឺប្រៀបដូចជាខ្នែង ហើយព្រះគ្រិស្តគឺប្រៀបដូចជាដើមទំពាំងបាយជូរ។ ខ្នែងមិនពិបាកនៅក្នុងការនៅជាប់នឹងដើមទំពាំងបាយជូរនោះទេ វាគ្រាន់តែ ពឹងផ្អែក និងផ្ញើជីវិតទៅលើដើមទំពាំងបាយជូរប៉ុណ្ណោះ ។

មិនខុសគ្នាពីគ្រិស្តបរិស័ទ ដោយសារជំនឿក៏អាចឲ្យយើងបានសម្រាក និងរីករាយជាមួយនឹងព្រះគ្រិស្តបានដែរ ។ ការរីករាយជាមួយនឹងមិត្តដ៏ល្អណាម្នាក់ មិនមែនមានន័យថាត្រូវតែសន្ទនាគ្នាជាប់រហូតនោះទេ ប៉ុន្តែ

ក៏មិនមែនមិនអើរពើរចំពោះគ្នានោះដែរ ។
ដោយគ្រាន់តែនៅជាមួយនឹងមិត្តសម្លាញ់របស់ខ្លួននោះក៏នាំមកនូវសេចក្ដីអំណរនៅហើយ ។

សរុបសេចក្ដីមក
មធ្យោបាយដ៏ល្អបំផុតដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់
គឺជាការរីករាយជាមួយនឹងព្រះអង្គជារៀងរហូត!
នឹកចាំពីទ្រង់នៅពេលលោកអ្នកភ្ញាក់ពីដំណេកនៅពេលព្រឹក
ហើយជារៀងរាល់ថ្ងៃត្រូវថ្វាយដាច់ដល់ព្រះអង្គ។
សូមអនុញ្ញាតឱ្យព្រះអង្គធ្វើជាមិត្តសំឡាញ់ដ៏ល្អបំផុតរបស់លោកអ្នក ។


Chapter 13